# ភ្ជាប់ផ្គុំរូបឡាន

រូបផ្គុំជាល្បែងមួយប្រភេទដែលកុមារចូលចិត្ត។ ការលេងល្បែងនេះគឺចាំបាច់ត្រូវប្រើខួរក្បាល វាជាល្បែងមួយដែលឱ្យកុមារយកបំណែកតូចៗដែលគេចាក់ច្របល់ចូលគ្នា មកផ្គុំឡើងវិញឱ្យបានសំរេចជារូបភាពដើម។ ដូច្នេះដើម្បីឱ្យកុមារមានអារម្មណ៍ថាខ្លួនឯងធ្វើបានសំរេចអ្វីមួយ មនុស្សធំត្រូវគិតអំពីរូបផ្គុំណាដែលសមស្របនឹងអាយុកុមារ ពីងាយស្រួលទៅលំបាក នោះគឺជាការគោរពសិទ្ធិកុមារ ព្រោះកុមារខ្លះចូលចិត្តលំបាក។

**[អាយុគោលដៅ]**

១. សំរាប់កុមារចាប់ពីអាយុ៣ឆ្នាំឡើងទៅ។

**[គោលបំណង]**

១. ឱ្យកុមារបានប្រើចលនាម្រាមដៃឱ្យបានញឹកញាប់ ត្រៀមមុនការសរសេរ។
២. ឱ្យកុមារប្រើភ្នែកពិនិត្យ សង្កេតលើផ្នែកខាងលើមានអ្វីខ្លះ ខាងមុខ ខាងក្រោយ និងខាងក្រោម ដើម្បីកំណត់ទីតាំងងាយស្រួលផ្គុំ។
៣. ឱ្យកុមារស្គាល់រាងមូល រាងការេ និងរាងចតុកោណភ្នាយ។
៤. ឱ្យកុមារមានការចងចាំទីតាំង និងទិស។
៥. ឱ្យកុមារស្គាល់ពណ៌។
៦. ឱ្យកុមារចេះប្រើការគិត។

**[របៀបបង្ហាញទៅកុមារ]**

១. មុនពេលពង្រាយបំណែកតូចៗចេញពីគ្នា:
   ១.១. សូមពិនិត្យមើលរូបភាព(ប្រើប្រាស់ការសង្កេត) ដោយពន្យល់និងបំផុសសំណួរពាក់ព័ន្ធនឹងអ្វីដែលបានឃើញ។
   ឧទាហរណ៍១: តើឡានមានកង់ចំនួនប៉ុន្មាន? នេះជារូបអ្វី? រូបឡាននេះមានអ្វីខ្លះ? ផ្នែកខាងលើមានអ្វីខ្លះ?
   ឧទាហរណ៍២: តើឡានដឹកអីវ៉ាន់ចំនួនប៉ុន្មានដុំ? ជាដើម។ល។
   ១.២. តាមរយៈការសួរសំណួរជាច្រើន កុមារអាចប្រើប្រាស់ការសង្កេត ហើយអាចជួយដល់ការចងចាំរបស់កុមារបាន។
២. ប្រើម្រាមដៃដកបំណែករាង៤ជ្រុង៦ដុំ រាងមូល២ដុំ រាងចតុកោណភ្នាយ១ដុំ របស់ឡានម្តងមួយៗចេញ។
៣. ស្វែងរកកន្លែងដែលដាក់ឱ្យត្រូវនូវតាមរាងនៃបំណែកបណ្តើរ ដាក់បំណែកនោះបញ្ចូលម្តងមួយៗបណ្តើរយ៉ាងទន់ភ្លន់។
៤. នៅពេលផ្គុំបានពី១〜៣ហើយ ដកបំណែករបស់ឡានទាំងមូលចេញឱ្យអស់ រួចរៀបផ្គុំឡើងវិញ។

[ចំណុចត្រូវប្រុងប្រយ័ត្ន]

១. សូមបង្ហាញកុមារនូវការដកនិងផ្គុំបំណែកនីមួយៗរបស់ឡានដោយទន់ភ្លន់ ។ រួចឱ្យកុមារសាកល្បងផ្គុំដោយដៃខ្លួនឯងផ្ទាល់ ។ ប្រសិនបើគ្រូផ្គុំដោយរញ្ជួររញ្ជៀមិនតាមលំដាប់លំដោយ នោះកុមារនឹងធ្វើតាម ដោយមានលក្ខណៈរញ្ជួររញ្ជៀជាងគ្រូ ទៅទៀត ។

២. បើទោះជាមានការពន្យល់តិចតួចក៏ដោយ តែសំខាន់គឺកុមារចាប់អារម្មណ៍លើការអនុវត្តជាក់ស្តែងរបស់គ្រូ ។ កុមារមិនពូកែមើលនិងស្តាប់ក្នុងពេលតែមួយទេ ។

៣. សូមធ្វើឱ្យកុមារចេះប្រើប្រាស់ម្រាមដៃ ។ ចលនាដែលប្រើប្រាស់ម្រាមដៃ អាចភ្ជាប់ទៅនឹងចលនានៃការកាន់សម និងស្លាបព្រា ការកាន់ខ្មៅដៃសរសេរជាដើម ។ល ។

[របៀបគិត]

១. សូមយកចិត្តទុកដាក់ចំពោះអាយុរបស់កុមារ និងភាពខុសគ្នារបស់មនុស្សដោយគិតអំពីការពិតតាមរយៈគ្រឿងផ្គុំឡានទាំងអស់គ្នា ។

[ចំណុចល្អរបស់គ្រឿងផ្គុំឡាន]

មានលក្ខណៈងាយស្រួលក្នុងការប្រើ ដូច្នេះធ្វើអោយកុមារមានអារម្មណ៍ថាខ្លួនឯងធ្វើបានសំរេចជោគជ័យអ្វីមួយ ។